NCAC

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម

NATIONAL COMMERCIAL ARBITRATION CENTRE

# ក្រមសីលធម៌ សម្រាប់សន្ធានការី

១៨ មីនា ២០២៣


គាំទ្រដោយ

IFC International Finance Corporation WORLD BANK GROUP

*Creating Markets, Creating Opportunities*

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Confederation

Federal Department of Economic Affairs,
Education and Research EAER
**State Secretariat for Economic Affairs SECO**

# មាតិកា


| | | |
|---|---|---|
| ១. | វិសាលភាព | ៣ |
| ២. | ពេលវេលា និងសមត្ថភាព | ៤ |
| ៣. | អព្យាក្រឹតភាព | ៤ |
| ៤. | ឯករាជភាព និងទំនាស់ផលប្រយោជន៍ | ៥ |
| ៥. | ដំណើរការ និងនីតិវិធី | ៧ |
| ៦. | ការដកខ្លួនចេញរបស់សន្ធានការី | ៩ |
| ៧. | ការបញ្ចប់សន្ធានកម្មដោយសន្ធានការី | ៩ |
| ៨. | កម្រៃសេវា | ១០ |
| ៩. | អវសានប្បញ្ញត្តិ | ១១ |

# ក្រមសីលធម៌សម្រាប់សន្ទានការី

## ១. វិសាលភាព

ក្រមសីលធម៌សម្រាប់សន្ទានការី (“**ក្រមសីលធម៌**”) នេះ អនុវត្តចំពោះបុគ្គលគ្រប់រូបដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការដ្ឋាន ដើម្បីបំពេញតួនាទីជាសន្ទានការីក្នុងសន្ទានកម្មដែលចាត់ចែងដោយ ម.ជ.ម. រួមទាំងបុគ្គលដែលមិនបានចុះឈ្មោះនៅក្នុងបញ្ជីសន្ទានការីរបស់ ម.ជ.ម.។

ក្រមសីលធម៌ជាផ្នែកមួយនៃវិធានស្ដីពីសន្ទានកម្មរបស់ ម.ជ.ម. (“**វិធានស្ដីពីសន្ទានកម្ម**”) និងអាចត្រូវបានកែសម្រួលដោយឡែកពីវិធានស្ដីពីសន្ទានកម្ម។ វាក្យស័ព្ទទាំងអស់ដែលបានកំណត់នៅក្នុងវិធានស្ដីពីសន្ទានកម្មអនុវត្តចំពោះក្រមសីលធម៌នេះ។

## ២. ពេលវេលា និងសមត្ថភាព

មុនពេលទទួលយកការតែងតាំង សន្ធានការីត្រូវបំពេញលក្ខខណ្ឌសមហេតុផលថា ខ្លួនអាចធ្វើដំណើរការសន្ធានកម្មប្រកបដោយសមត្ថភាព និងឆាប់រហ័ស។

ប្រសិនបើក្នុងអំឡុងពេលធ្វើសន្ធានកម្ម សន្ធានការីមានអារម្មណ៍ថា ខ្លួនកំពុងឃ្លាតចេញពីកម្រិតសមត្ថភាពរបស់ខ្លួន សន្ធានការីនោះគួរធ្វើសកម្មភាពមួយ ឬច្រើនដូចតទៅ៖ (ក) ជូនដំណឹងដល់គូភាគី (ខ) ផ្អាកសន្ធានកម្ម (គ) ស្វែងរកការប្រឹក្សាយោបល់ពីទីប្រឹក្សា ឬអ្នកជំនាញ (ឃ) បញ្ចូលសហសន្ធានការី ឬសន្ធានការីជំនួស ឬបុគ្គលផ្សេងទៀត ឬ (ង) ដកខ្លួនចេញពីសន្ធានកម្ម។

## ៣. អព្យាក្រឹតភាព

ដើម្បីអនុលោមតាមកាតព្វកិច្ចក្នុងការរក្សាអព្យាក្រឹតភាពក្រោមវិធានស្តីពីសន្ធានកម្ម សន្ធានការីត្រូវបដិសេធ ឬដកខ្លួនចេញពីសន្ធានកម្មប្រសិនបើសន្ធានការីមិនអាចដំណើរការសន្ធានកម្មប្រកបដោយភាពអព្យាក្រឹតបានទេ។ អព្យាក្រឹតភាពគឺសេរីភាពពីឆន្ទាគតិ ពីការលម្អៀង ឬពីការមានបុរេវិនិច្ឆ័យចំពោះឬប្រឆាំងភាគីណាមួយទោះបីតាមរយៈពាក្យសម្តី ឬសកម្មភាពក៏ដោយ។ អព្យាក្រឹតភាព គឺជាការប្តេជ្ញាចិត្តក្នុងការបម្រើអ្នកចូលរួមក្នុងសន្ធានកម្មទាំងអស់ ដែលផ្ទុយពីការបម្រើតែភាគីម្ខាង និងការជៀសវាងនូវរាល់សកម្មភាព ដែលបង្ហាញឱ្យឃើញពីភាពមិនអព្យាក្រឹត្យ ឬបុរេវិនិច្ឆ័យណាមួយ។

សន្ទានការីគួរព្យាយាមផ្តល់នូវដំណើរការប្រកបដោយភាពយុត្តិធម៌តាមនីតិវិធី ដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការចូលរួម។ ប្រសិនបើសន្ទានការីក្លាយជាអសមត្ថភាពក្នុងការរក្សាអព្យាក្រឹតភាព សន្ទានការីនោះគួរដកខ្លួនចេញភ្លាមៗ។

## ៤. ឯករាជភាព និងទំនាស់ផលប្រយោជន៍

ដើម្បីអនុលោមតាមកាតព្វកិច្ចក្នុងការរក្សាឯករាជភាពក្រោមវិធានស្តីពីសន្ទានកម្ម សន្ទានការីត្រូវធ្វើការសាកសួរសមហេតុផលដើម្បីពិនិត្យអំពីវត្តមាននៃទំនាស់ផលប្រយោជន៍ដែលមានស្រាប់ ឬយល់ឃើញថាអាចមាន ដែលអាចបង្កឱ្យមានការសង្ស័យនៅក្នុងការយល់ឃើញរបស់គូភាគី។ អាស្រ័យដូចនេះ សន្ទានការីត្រូវធានាថាខ្លួន៖

(ក) ពុំមានទំនាក់ទំនងជាមួយអ្នកចូលរួមណាមួយនៅក្នុងសន្ទានកម្មណាមួយឡើយ ទោះបីពីអតីតកាល ឬបច្ចុប្បន្ន ជាលក្ខណៈបុគ្គល ឬតាមការប្រកបវិជ្ជាជីវៈ ដែលបង្កឱ្យមានសំណួរសមហេតុផលអំពីឯករាជភាពរបស់សន្ទានការី

(ខ) ពុំមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ (ដោយផ្ទាល់ ឬប្រយោល) ពីភាគីណាមួយ ឬលទ្ធផលនៃសន្ទានកម្មនោះទេ

(គ) ពុំមានព័ត៌មានសម្ងាត់អំពីគូភាគី ឬវិវាទដែលទទួលបានពីប្រភពក្រៅពីសន្ទានកម្មនោះទេ (មិនរាប់បញ្ចូលព័ត៌មានសម្ងាត់ដែលភាគីណាមួយ អាចប្រកាសបង្ហាញដល់សន្ទានការីនៅក្នុងដំណើរការនីតិវិធីសន្ទានកម្ម)។

កាតព្វកិច្ចនេះបន្តក្នុងដំណើរការសន្ទានកម្មទាំងមូល។ ក្នុងករណីមានចម្ងល់ សន្ទានការីត្រូវតែប្រកាសបង្ហាញដល់គូភាគីនូវរាល់ស្ថានភាព ឬអង្គហេតុដែលអាចបង្កើតបានជាទំនាស់ផលប្រយោជន៍ ឬអាចត្រូវបានយល់ឃើញថាជាទំនាស់ផលប្រយោជន៍។

ប្រសិនបើទំនាស់ផលប្រយោជន៍របស់សន្ទានការីអាចត្រូវបានយល់ឃើញថា ធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃសន្ទានកម្ម សន្ទានការីត្រូវដកខ្លួនចេញ ឬបដិសេធក្នុងការបន្តសន្ទានកម្មដោយមិនគិតពីបំណង ឬការព្រមព្រៀងរបស់គូភាគីដែលផ្ទុយពីនេះ។

បន្ទាប់ពីបញ្ចប់សន្ទានកម្ម សន្ទានការីមិនគួរបង្កើតទំនាក់ទំនងមួយផ្សេងទៀតជាមួយអ្នកចូលរួមណាមួយក្នុងរាល់កិច្ចការដែលអាចចោទជាសំណួរអំពីសុចរិតភាពនៃសន្ទានកម្មនោះទេ។ ក្នុងករណីដែលសន្ទានការីអភិវឌ្ឍនូវទំនាក់ទំនងជាលក្ខណៈបុគ្គល ឬជាលក្ខណៈវិជ្ជាជីវៈជាមួយគូភាគី រូបវន្តបុគ្គល ឬស្ថាប័នផ្សេងទៀតបន្ទាប់ពីបញ្ចប់សន្ទានកម្មដែលពួកគេបានចូលរួម សន្ទានការីគួរពិចារណាអំពីកត្តាដូចជា ពេលវេលាដែលបានកន្លងផុតទៅបន្ទាប់ពីបញ្ចប់សន្ទានកម្ម លក្ខណៈនៃទំនាក់ទំនងដែលបានបង្កើតឡើង និងសេវាកម្មដែលបានផ្តល់ជូន ដើម្បីកំណត់ថាតើទំនាក់ទំនងនោះអាចបង្កើតទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬតាមការយល់ឃើញឬទេ។

## ៥. ដំណើរការ និងនីតិវិធី

### ការចូលរួមរបស់គូភាគី

សន្ទានការីត្រូវធានាថាគ្រប់ភាគីទាំងអស់មានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមក្នុងនីតិវិធីនេះ។ សន្ទានការីត្រូវដំណើរការសន្ទានកម្ម ប្រកបដោយការយកចិត្តទុកដាក់ចំពោះភាពយុត្តិធម៌ផ្នែកនីតិវិធីចំពោះភាគីទាំងអស់ និងធានាថាភាគីទាំងអស់មានឱកាសគ្រប់គ្រាន់ក្នុងការបង្ហាញរឿងហេតុរបស់ខ្លួន។

### ការពន្យល់អំពីនីតិវិធីសន្ទានកម្ម និងវិធានស្ដីពីសន្ទានកម្ម

សន្ទានការីនឹងព្យាយាមក្នុងការធានាថាគូភាគី និងអ្នកតំណាងរបស់ពួកគេយល់អំពីនីតិវិធីសន្ទានកម្ម ជាអាទិ៍៖

(ក) បង្ហាញអំពីភាពខុសគ្នារវាងសន្ទានកម្ម និងនីតិវិធីដោះស្រាយវិវាទផ្សេងៗទៀត ជាពិសេសពាក់ព័ន្ធនឹងសិទ្ធិរបស់គូភាគីក្នុងការសម្រេចដោយខ្លួនឯង និងភាពស្ម័គ្រចិត្តនៃនីតិវិធី

(ខ) ភារកិច្ចរបស់គូភាគីក្នុងការព្យាយាមធ្វើការសះជាប្រកបដោយភាពស្មោះត្រង់ និងពិតប្រាកដ

(គ) តួនាទីរបស់មេធាវី ទីប្រឹក្សា និងរាល់អ្នកចូលរួមផ្សេងទៀតនៅក្នុងសន្ទានកម្ម

(ឃ) បញ្ជាក់ឡើងវិញថា សន្ទានការីមិនមែនជាអ្នកតំណាងតាមផ្លូវច្បាប់ ឬអ្នកជំនាញបច្ចេកទេសសម្រាប់ភាគីណាមួយឡើយ

(ង) សន្ទានការីពុំមានសមត្ថកិច្ចក្នុងការចាប់បង្ខំគូភាគីឱ្យទទួលយកដំណោះស្រាយណាមួយនោះទេ

(ច) សន្ទានការីនឹងចែករំលែកព័ត៌មានដែលទទួលបានពីកិច្ចប្រជុំឯកជននៅពេលដែលសន្ទានការីយល់ឃើញថា សមរម្យ និងមានប្រយោជន៍ ក្នុងលក្ខខណ្ឌគោរពតាមវិធានពាក់ព័ន្ធនឹងការសម្ងាត់

(ឆ) សន្ទានការីអាចបង្ហាញការយល់ឃើញរបស់ខ្លួនតែនៅពេលដែលគូភាគីស្នើសុំនៅដំណាក់កាលក្រោយៗមកទៀតនៃសន្ទានកម្មតែប៉ុណ្ណោះ ហើយសន្ទានការីមានសេរីភាពក្នុងការបដិសេធ ផ្តល់នូវការយល់ឃើញរបស់ខ្លួន ហើយការផ្តល់នូវការយល់ឃើញបែបនេះមិនមែនជាការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ ឬផ្នែកបច្ចេកទេសនោះទេ និងមិនចងកាតព្វកិច្ចចំពោះគូភាគីឡើយ

(ជ) ពន្យល់អំពីខ្លឹមសារនៃវិធានស្តីពីសន្ទានកម្ម ជាពិសេសពាក់ព័ន្ធនឹងកិច្ចប្រជុំរួម និងកិច្ចប្រជុំឯកជន និងការសម្ងាត់។

សន្ទានការីនឹងសាកសួរ ប្រសិនបើគូភាគីមានបំណងកែប្រែបទប្បញ្ញត្តិណាមួយនៃវិធាន តាមរយៈលក្ខខណ្ឌនៃការធ្វើសន្ទានកម្ម។

## យោបល់ឯករាជ្យ

សន្ទានការីមិនអាចធានាថាភាគីនីមួយៗបានសម្រេចចិត្តជាក់លាក់ដោយសេរី ផ្អែកតាមព័ត៌មានគ្រប់ជ្រុងជ្រោយឡើយ ប៉ុន្តែប្រសិនបើសមរម្យ សន្ទានការីគួរប្រាប់ឱ្យគូភាគីដឹងអំពីសារៈ-សំខាន់នៃការពិគ្រោះយោបល់ជាមួយអ្នកប្រកបវិជ្ជាជីវៈផ្សេងទៀតដើម្បីអោយពួកគេអាចសម្រេចចិត្តដោយផ្អែកតាមព័ត៌មានគ្រប់ជ្រុងជ្រោយ។

## ៦. ការដកខ្លួនចេញរបស់សន្ធានការី

បន្ថែមពីលើករណីដែលបានរៀបរាប់ខាងលើស្តីពីភារកិច្ចរបស់សន្ធានការី ក្នុងការដកខ្លួនចេញពីដំណើរការនីតិវិធីដោយសារមូលហេតុអព្យាក្រឹតភាព និងឯករាជភាព សន្ធានការីត្រូវដកខ្លួនចេញពីសន្ធានកម្ម និងជូនដំណឹងភ្លាមៗដល់អគ្គលេខាធិការដ្ឋានអំពីការដកខ្លួននោះនៅពេលដឹងថាខ្លួនបានបំពានវិធានស្តីពីសន្ធានកម្ម និង/ឬក្រមសីលធម៌នេះ។

## ៧. ការបញ្ចប់សន្ធានកម្មដោយសន្ធានការី

សន្ធានការីត្រូវបញ្ចប់សន្ធានកម្ម និងជូនដំណឹងភ្លាមៗដល់អគ្គលេខាធិការដ្ឋាន អំពីការបញ្ចប់នោះក្នុងករណីមានព្រឹត្តិការណ៍ណាមួយខាងក្រោម៖

(ក) ប្រសិនបើមានសំណើសុំដោយភាគីណាមួយដើម្បីឱ្យសន្ធានការីបំពានវិធានស្តីពីសន្ធានកម្ម និង/ឬក្រមសីលធម៌នេះ ឬច្បាប់ជាធរមានណាមួយហើយសន្ធានការីមិនអាចបន្តសន្ធានកម្មដោយគ្មានការយល់ព្រមតាមសំណើនោះ

(ខ) ប្រសិនដឹងច្បាស់លាស់ថាគោលបំណងនៃសន្ធានកម្មគឺដើម្បីបំពានច្បាប់ជាធរមានណាមួយ

(គ) ប្រសិនបើអតុល្យភាពអំណាចរវាងគូភាគី ទំនងជានាំឱ្យមានការសះជាធ្វើឡើងក្រោមការបង្ខិតបង្ខំ

(ឃ) ប្រសិនបើគូភាគីទំនងជាមិនឈានដល់ការសះជានោះទេ

(ង) ប្រសិនបើមើលឃើញថាការបន្តនីតិវិធីអាចធ្វើឱ្យខូចខាត ឬអន្តរាយដល់គូភាគីណាមួយ ដូចជានៅក្នុងស្ថានភាពដែលគូភាគី និង/ឬអ្នកតំណាងរបស់ពួកគេព្យាយាមប្រើប្រាស់ដំណើរការសន្ធានកម្មមិនត្រឹមត្រូវដើម្បីសម្រេចបាននូវគោលបំណងផ្សេងទៀតដូចជា៖

(i) ពន្យារដំណើរការនីតិវិធី ដោយសង្ឃឹមថានឹងបន្តនូវការរៀបចំដែលមានស្រាប់ ឬពន្យារការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ឬទទួលបានអត្ថប្រយោជន៍ផ្សេងទៀត ឬ

(ii) អូសបន្លាយពេលវេលាដើម្បីបំបាត់ ឬលាក់ទ្រព្យសម្បត្តិ ឬធ្វើសកម្មភាពដោយទុច្ចរិត

(iii) ករណីដែលតាមការយល់ឃើញរបស់សន្ធានការី គូភាគីមួយ ឬច្រើន និង/ឬអ្នកតំណាងរបស់ពួកគេហាក់បីដូចជាកំពុងធ្វើសកម្មភាពដោយទុច្ចរិត។

ក្នុងករណីណាមួយខាងលើ ប្រសិនបើអាចធ្វើបាន សន្ធានការីគួរជូនដំណឹងសមហេតុផលដល់អ្នកចូលរួម និងអាចជួយគូភាគីក្នុងការពិចារណាជម្រើសនីតិវិធីបន្តទៀត សម្រាប់ការដោះស្រាយវិវាទរបស់ពួកគេ។

## ៨. កម្រៃសេវា

សន្ធានការីត្រូវទទួលប្រាក់កម្រៃរបស់ខ្លួន (កម្រៃសេវា និងការចំណាយផ្សេងៗ) ស្របតាមលក្ខខណ្ឌនៃការតែងតាំងសន្ធានការីដោយ ម.ជ.ម. និងដោយផ្ទាល់ពី ម.ជ.ម. ប៉ុណ្ណោះ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១ (តារាងកម្រៃសេវា ម.ជ.ម.) នៃវិធានស្តីពីសន្ធានកម្ម។

សន្ធានការីមិនត្រូវចូលរួមក្នុងការរៀបចំជាលក្ខណៈឯកជនណាមួយជាមួយភាគីណាមួយ ក្នុងគោលបំណងបង់កម្រៃសេវា ឬប្រាក់បំណាច់ផ្សេងទៀតនោះទេ ឬក្នុងករណីផ្សេងពីនេះ ក្នុងគោលបំណងទទួលបានអត្ថប្រយោជន៍ណាមួយពីការបំពេញតួនាទីជាសន្ធានការីនៅក្នុងសន្ធានកម្ម រួមទាំងការទទួលអំណោយជាវត្ថុ ឬសាច់ប្រាក់ ឬសេវាកម្មពីគូភាគី ឬអ្នកតំណាង ឬជំនួយការរបស់ពួកគេឡើយ។

## ៩. អវសានប្បញ្ញត្តិ

ក្រមសីលធម៌នេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

ក្រមសីលធម៌នេះមានអានុភាពអនុវត្តចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ តទៅ។

ថ្ងៃសៅរ៍ ១២ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម**

**ប្រធាន**

**សាន គីរី**

WWW.NCAC.ORG.KH